00858098

F30/4/corr-1

# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 02 / 11 / 2012
ម៉ោង (Time/Heure) : 10 : 30
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: UCH Arun

## សំណើសុំការកែតម្រូវ

**សំណុំរឿងលេខ៖** 001/18-07-2007-ECCC/SC

| កែលើឯកសារលេខ៖ | ERN(s): | កាលបរិច្ឆេទ៖ | ប្រភេទកំណែ៖ |
|---|---|---|---|
| F30/4 | 00857692-00857693 | 02/11/12 | ☒ កែលើឯកសារដើម<br>☐ កែលើឯកសារបកប្រែ<br>☐ រៀបចំចាត់ថ្នាក់ឡើងវិញ |

| មូលហេតុនៃការកែតម្រូវ៖ |
|---|
| មានកំហុសលើការសរសេរ ចំនួន ០៣។ |

| សេចក្ដីលម្អិតនៃការកែតម្រូវ៖ |
|---|
| សូមមើលឯកសារភ្ជាប់ |

ស្នើដោយ៖ (SC) Theoun, Pham — ហត្ថលេខា៖ [signature]

បានទទួលការឯកភាពពីក្រឡាបញ្ជី(ចំពោះឯកសារដើម)៖ — ហត្ថលេខា៖

បានទទួលការឯកភាពពីអង្គភាពបកប្រែភាសា(ចំពោះការបកប្រែ)៖ — ហត្ថលេខា៖

រួមមាន ព័ត៌មានទំនាក់ទំនងលម្អិតរបស់ជនរងគ្រោះដែលមិនមែនជាដើមបណ្តឹងរដ្ឋប្បវេណី កំណត់ហេតុនៃដំណើរការនីតិវិធីដែលបានធ្វើឡើងជាអសាធារណៈ និងឯកសារសម្ងាត់ដែលត្រូវបានដាក់បញ្ចូលនៅក្នុងសំណុំរឿងផ្សេងទៀត លើកលែងតែក្នុងករណីដែលសំអាងហេតុត្រូវរក្សាការសម្ងាត់លែងមានសុពលភាពទៀត[6]។ បន្ថែមពីលើនេះទៀត ត្រូវរក្សាជាឯកសារសម្ងាត់បំផុតចំពោះឯកសារនានា ឬផ្នែកណាមួយនៃឯកសារទាំងនោះដែលបច្ចុប្បន្នត្រូវបានធ្វើចំណាត់ថ្នាក់ថាជា 'ឯកសារសម្ងាត់បំផុត' ក្នុងនោះរួមមាន សំណើសុំវិធានការការពារ និងឯកសារជាប់ពាក់ព័ន្ធ ឯកសារនិងព័ត៌មានដែលត្រូវមានវិធានការការពារ ព្រមទាំងព័ត៌មានដែលទាក់ទងនឹងសុខភាពរបស់ជនសង្ស័យ ជនត្រូវចោទ និងជនជាប់ចោទ លើកលែងតែក្នុងករណីដែលសំអាងហេតុត្រូវរក្សាការសម្ងាត់លែងមានសុពលភាពទៀត[7]។ ឯកសារទាំងអស់ផ្សេងទៀតត្រូវធ្វើចំណាត់ឡើងវិញ[8] អាស្រ័យលើការកោសលុបចាំបាច់ណាមួយ[9]។

3. នៅថ្ងៃទី ៦ ខែ កញ្ញា ឆ្នាំ ២០១២ ប្រធានអង្គជំនុំជម្រះតុលាការកំពូលបានបង្គាប់ឱ្យអង្គភាពបណ្ណសារធ្វើដំណើរការនិងជូនដំណឹងពីឯកសារទាំងអស់ដែលត្រូវបានធ្វើចំណាត់ថ្នាក់ឡើងវិញភ្លាមៗថាជា 'ឯកសារសាធារណៈ'[10]។ អាស្រ័យហេតុនេះ អង្គភាពបណ្ណសារ នៃ អ.វ.ត.ក បានធ្វើដំណើរការ និងជូនដំណឹងពីឯកសារទាំងអស់ដែលត្រូវបានធ្វើចំណាត់ថ្នាក់ឡើងវិញថាជា 'ឯកសារសាធារណៈ'[11]។ ឯកសារផ្សេងទៀតត្រូវបានកំណត់បង្ហាញនៅក្នុងដីកាបង្គាប់របស់ប្រធានអង្គជំនុំជម្រះតុលាការកំពូល ដែលតម្រូវឱ្យធ្វើការកោសលុបមុនពេលធ្វើចំណាត់ថ្នាក់ឡើងវិញ[12]។ ដោយសារមានការកោសលុបលើឯកសារ[13] និងការកំណត់អត្តសញ្ញាណឯកសារមួយចំនួនបន្ថែមទៀតដែលអាចត្រូវធ្វើចំណាត់ថ្នាក់ឡើងវិញដោយគ្មានការកោសលុប[14]នោះ ទើបឥឡូវនេះ ឯកសារទាំងនេះ ត្រូវបានរៀបចំរួចរាល់ដើម្បីធ្វើចំណាត់ថ្នាក់ឡើង

Deleted: ចំនួន ២៣៤

Deleted: ចំនួន ៦៨

Deleted:

Deleted: អស់

Deleted: នោះ

Deleted:

Deleted:

[6] សេចក្តីសម្រេចលើគោលការណ៍ណែនាំ កថាខណ្ឌ ៧(ខ)។

[7] សេចក្តីសម្រេចលើគោលការណ៍ណែនាំ កថាខណ្ឌ ៧(គ)។

[8] សេចក្តីសម្រេចលើគោលការណ៍ណែនាំ កថាខណ្ឌ ៧(ក)។

[9] សេចក្តីសម្រេចលើគោលការណ៍ណែនាំ កថាខណ្ឌ ៧(ឃ)។

[10] ឯកសារ F30/2 (សម្ងាត់បំផុត), ដីការបស់ប្រធានអង្គជំនុំជម្រះតុលាការកំពូល ថ្ងៃទី ៦ ខែ កញ្ញា ឆ្នាំ ២០១២ (ដីកាបង្គាប់របស់ប្រធានអង្គជំនុំជម្រះតុលាការកំពូល) កថាខណ្ឌ ៣ ឧបសម្ព័ន្ធ។

[11] អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញថា ឯកសារទាំងអស់បែបនេះ ឥឡូវនេះមានកំណត់សម្គាល់ដោយត្រាប្រើប្រាស់ដោយអង្គភាពបណ្ណសារ ដាក់ថា "ត្រូវបានធ្វើចំណាត់ឡើងវិញជាឯកសារសាធារណៈ ថ្ងៃទី ៦ ខែ កញ្ញា ឆ្នាំ ២០១២"។ មើល ឧបសម្ព័ន្ធ ក។

[12] ដីកាបង្គាប់របស់ប្រធានអង្គជំនុំជម្រះតុលាការកំពូល កថាខណ្ឌ ៣ (៣)។

[13] មើលឧបសម្ព័ន្ធ ក។

[14] មើលឧបសម្ព័ន្ធ ខ។

00858100

F30/4/corr-1



វិញជា 'ឯកសារសាធារណៈ'។ ឯកសារសេសសល់ផ្សេងទៀត ដែលបច្ចុប្បន្នកំពុងត្រូវបានធ្វើការកោសលុបឲ្យបានត្រឹមត្រូវ[15] ឬត្រូវបានកំណត់ថាត្រូវធ្វើចំណាត់ថ្នាក់ឡើងវិញនៅពេលអនាគតនោះ នឹងត្រូវបានធ្វើចំណាត់ថ្នាក់ឡើងវិញយ៉ាងឆាប់រហ័ស។

4. អង្គជំនុំជម្រះតុលាការកំពូលពិចារណាយល់ឃើញថា វាក៏មានប្រយោជន៍ខាងតម្លាភាពផងដែរដែលត្រូវចេញផ្សាយនូវឧបសម្ព័ន្ធ[16]នៃឯកសារដែលត្រូវបានធ្វើចំណាត់ឡើងវិញរួចហើយ[17] ព្រមទាំងឯកសារដែលត្រូវបានធ្វើចំណាត់ថ្នាក់ឡើងវិញដោយសេចក្តីសម្រេចនេះ[18]។

## ផ្នែកសម្រេចសេចក្តី

យោងតាមសំអាងហេតុខាងលើ **អង្គជំនុំជម្រះតុលាការកំពូល សម្រេច៖**

**បង្គាប់**ថា ឯកសារដែលបានកែតម្រូវដូចមានបង្ហាញនៅក្នុងឧបសម្ព័ន្ធ ក នៃសេចក្តីសម្រេចនេះ ត្រូវធ្វើចំណាត់ថ្នាក់ឡើងវិញថាជា 'ឯកសារសាធារណៈ' ហើយ

បង្គាប់ថា ឯកសារទាំងនេះដែលមានបង្ហាញក្នុងឧបសម្ព័ន្ធ ខ នៃសេចក្តីសម្រេចនេះ ត្រូវធ្វើចំណាត់ថ្នាក់ឡើងវិញថាជា 'ឯកសារសាធារណៈ'។

Deleted: និង ខ

Formatted: Justified

Deleted: ។

រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១២

**ប្រធានអង្គជំនុំជម្រះតុលាការកំពូល**

E.C.C.C * C.E.T.C * CHAMBER CHAMBRE DE LA COUR SUPRÊME

**គង់ ស្រ៊ិម**

---

[15] ទោះបីយ៉ាងណាក៏ដោយ អង្គជំនុំជម្រះតុលាការកំពូលពិចារណាថា នៅពេលដែលឯកសារណាមួយជាភាសាណាមួយត្រូវបានធ្វើចំណាត់ថ្នាក់ឡើងវិញ នោះឯកសារនេះក្នុងភាសាមួយទៀតត្រូវមានចំណាត់ថ្នាក់ឯកសារដូចគ្នាតាមដីកាបង្គាប់។

[16] មើលឧបសម្ព័ន្ធ គ។

[17] ដីកាបង្គាប់របស់ប្រធានអង្គជំនុំជម្រះតុលាការកំពូល កថាខណ្ឌ ៤ (ពិចារណាថា បញ្ជីឯកសារទាំងអស់ដែលត្រូវបានធ្វើចំណាត់ថ្នាក់ឡើងវិញក្នុងអំឡុងពេលត្រួតពិនិត្យឡើងវិញលើសំណុំឯកសារនៃសំណុំរឿង ០០១) ។

[18] មើលឧបសម្ព័ន្ធ ក។